ពលរដ្ឋខ្លាំង ជាតិខ្លាំង
STRONG PEOPLE STRONG NATION

# វេទិកាពលរដ្ឋ
FORUM FOR THE PEOPLE

សហរដ្ឋអាមេរិក ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២២

## សេចក្តីថ្លែងការណ៍
## លោក ហ៊ុន សែន បើនៅស្គាល់ឋានៈខ្លួនជានាយករដ្ឋមន្ត្រី
## ត្រូវដើរតួនាទីផ្សះផ្សាជាតិ ឈប់ធ្វើមនោគមវិជ្ជាបំពុលសម្អប់ពង្វក់សង្គម

**វេទិកាពលរដ្ឋ** មើលឃើញថា រយៈពេលចុងក្រោយនេះ ជម្លោះរវាងលោក **ហ៊ុន សែន** និង លោក **សម រង្ស៊ី** ក្លាយជាសង្គ្រាមមនោគមវិជ្ជានយោបាយប្រទូសរ៉ាយដណ្តើមឈ្នះបែបជាបុគ្គល ផ្ទុយពីបំណងប្រាថ្នារបស់ប្រជាពលរដ្ឋខ្មែរទូទៅ ដែលចង់ឃើញការសម្របសម្រួលផ្សះផ្សាគ្នា ដើម្បីដោះស្រាយវិបត្តិធំៗរបស់ជាតិ ជាពិសេស ទុក្ខវេទនារបស់ប្រជាពលរដ្ឋម្ចាស់ប្រទេស។

**វេទិកាពលរដ្ឋ** យល់ថា លោក **ហ៊ុន សែន** ក្នុងនាមជាអ្នកដឹកនាំប្រទេស គឺជាអ្នកមានតួនាទីសំខាន់ជាងគេ ក្នុងការនាំមុខបំពេញកាតព្វកិច្ចផ្សះផ្សាបង្រួបបង្រួមជាតិ ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ **តាមស្មារតីរដ្ឋធម្មនុញ្ញនិងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ២៣តុលា១៩៩១។** ប៉ុន្តែ លោក **ហ៊ុន សែន** បែរជាបង្កើតមនោគមវិជ្ជានយោបាយ «**ហ៊ុន សែន និយម**» មានលក្ខណៈបំពុលសម្អប់ ដែលមានកត្តាកំណត់ លើចិត្តសាស្ត្រញុះញង់បំបែកបំបាក់ និង ពង្វក់ពលរដ្ឋខ្មែរ ឲ្យស្អប់ខ្ពើមចងអាឃាតគ្នាទៅវិញ។

**វេទិកាពលរដ្ឋ** អំពាវនាវឲ្យលោក **ហ៊ុន សែន** បោះបង់មនោគមវិជ្ជាពង្វក់បំពុលសម្អប់នេះ ពីព្រោះនេះគឺជានយោបាយដែលងាយធ្វើឲ្យសង្គមខ្មែរបែកបាក់កាន់តែធំ និង ផ្តល់ផលដ៏ធំធេងដល់មហិច្ឆតាឈ្លានពានរបស់បរទេស។ លោក **ហ៊ុន សែន** ពិតជាដឹងថា ពេលយើងជាខ្មែរកំពុងវក់ និង ពុលដោយការស្អប់គ្នា ពួកអ្នកដែលពេញចិត្តបំផុតនឹងស្ថានភាពនេះ គឺបរទេសឈ្លានពាន។ ដូច្នេះ បើលោក **ហ៊ុន សែន** មិនបម្រើមហិច្ឆតាឈ្លានពានរបស់បរទេសណាមួយទេ *នោះលោក ហ៊ុន សែន ត្រូវងាកទៅដើរតួនាទីផ្សះផ្សាជាតិក្នុងឈ្មោះជានាយករដ្ឋមន្ត្រីរបស់ប្រទេសជាតិ មិនត្រូវទ្បំទ្បូកនឹងគំនិតអំណាចបុគ្គល ហួងហែងកាងបក្សសង្កត់ជាតិឡើយ។*

ជាការពិតណាស់ថា ការសម្របសម្រួលរវាងលោក **ហ៊ុន សែន** និង លោក **សម រង្ស៊ី** ពេលនេះ ជារឿងស្មុគស្មាញពិបាកទៅរួចភ្លាមៗ ដោយសារជម្លោះនៃអ្នកនយោបាយទាំងពីរ ធ្លាក់ចូលលក្ខណៈបុគ្គល វាយប្រហារចោទប្រកាន់គ្នា ដល់ជម្រៅបន្ទុកពូជពង្សគ្រួសារជ្រុលពេក។ ប៉ុន្តែ បើលោក **ហ៊ុន សែន** នៅរក្សាស្មារតីជាអ្នកដឹកនាំជាតិ គាត់គួរពិចារណាថា បច្ចុប្បន្ននេះ ក្រៅពីលោក **សម រង្ស៊ី** ក៏លោក **ហ៊ុន សែន** គួរបើកចិត្ត រកការជជែកសម្រួលនយោបាយជាមួយលោក **កឹម សុខា** ដើម្បីបន្ធូរបន្ទុកវិបត្តិប្រទេសជាតិដែរ។

ជាក់ស្តែង លោក **កឹម សុខា** កំពុងធ្វើទុក្ករកម្មនយោបាយ ប្រកាន់ធម៌អហិង្សា និង ការផ្សះផ្សាជាតិជានិច្ច ហើយច្រើនឆ្នាំចុងក្រោយនេះ លោក **កឹម សុខា** មិនធ្លាប់ប្រើសារប្រទូសនយោបាយបុគ្គលឡើយ។ ហេតុនេះ បើលោក **ហ៊ុន សែន** នៅតែមានលេសមិនរកដំណោះស្រាយនយោបាយផ្សះផ្សាជាតិ ដោយចាប់ផ្តើមជាមួយលោក **កឹម សុខា** ទៀត នោះគឺច្បាស់ណាស់ថា លោក **ហ៊ុន សែន** គ្រាន់តែជានាយករដ្ឋមន្ត្រី ដែលចេះត្រឹមតែការពារកិត្តិយសបុគ្គលខ្លួន គ្រួសារ**ហ៊ុន** និងបំពេញបំណងឈ្លានពានរបស់បរទេស។

**វេទិកាពលរដ្ឋ** ចង់ឃើញមានការផ្សះផ្សាផ្ទៃក្នុងជាតិទាំងអស់គ្នា ដោយមិនផាត់ចោលបុគ្គលណាទេ ហើយក៏រឹតតែមិនអាចរុញចេញទៅទៀត នូវអ្នកនយោបាយសក្តានុពលដូចលោក **សម រង្ស៊ី**។ យ៉ាងណា ដំណាក់កាលនេះ យើងខ្ញុំយល់ថា យ៉ាងហោចណាស់ក៏គួរបើកទំព័រដោះស្រាយនយោបាយ **ហ៊ុន សែន-កឹម សុខា** ដែរ បើលោក **ហ៊ុន សែន** នៅចាត់ទុកខ្លួនគាត់ជានាយករដ្ឋមន្ត្រីជាតិ។៚

**ប្រធាន វេទិកាពលរដ្ឋ**

**កឹម សុខ**

Address: 58 Poplar Street, Plains PA 18 705, USA